សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីរដូវវស្សា ដែលយើងហៅបានម្យ៉ាងទៀត គេហៅថារដូវភ្លៀង។ អញ្ចឹងជាទូទៅនៅក្នុងប្រទេសកម្ពុជា យើងហៅថាខែភ្លៀង ឬក៏រដូវភ្លៀង។ ដែល ដោយសារតែនៅក្នុងប្រទេសកម្ពុជា គឺជា[...]នៅប្រទេសដែលនៅក្នុងតំបន់អាស៊ីប៉ែកអាគ្នេយ៍ អញ្ចឹងគឺជាប្រទេសដែលនៅក្នុងតំបន់ត្រូពិក ដូច្នេះហើយរដូវគឺត្រូវបានបែងចែកចេញជាពីរធំៗ ដែលមានរដូវវស្សា និងរដូវប្រាំង ដែលរដូវវស្សា គឺជារដូវដែលមានភ្លៀងធ្លាក់ ចំណែកឯរដូវប្រាំង គឺអត់មានភ្លៀងធ្លាក់ទេ គឺពេលខ្លះគឺក្តៅ ហើយពេលខ្លះគឺត្រជាក់។ អញ្ចឹងរដូវទាំងពីរគឺបែងចែកចេញជាប្រាំមួយខែម្នាក់ បានន័យថាប្រាំមួយខែរដូវវស្សា និងប្រាំមួយខែទៀតរដូវប្រាំង។ ដោយមានភ្លៀងធ្លាក់រយៈពេលប្រាំមួយខែ ហើយមេឃរាំង អត់មានភ្លៀង រយៈពេលប្រាំមួយខែ ដែលខុសពីរដូវដែលនៅតំបន់អឺរ៉ុប តំបន់នៅប៉ែកអឺរ៉ុប ដែលមានរដូវចំនួនបួន ដែលយើងឃើញមានដូចជា រដូវស្លឹកឈើជ្រុះ រដូវធ្លាក់ទឹកកក រដូវក្តៅ រដូវលំហើយជាដើម ក៏ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា គឺអត់មានរដូវបួននោះទេ គឺមានរដូវតែពីរតែប៉ុណ្ណោះ គឺរដូវប្រាំង និងរដូវវស្សា។

អញ្ចឹងយើងមកមើលរូបភាពទាំងអស់គ្នា ដែលយើងឃើញនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានទីក្រុងមួយ ជារូបភាពទីក្រុង ដែលយើងឃើញនៅក្នុងទីក្រុងនោះ គឺមានអគារតូចធំជាច្រើន អញ្ចឹងមានអគារតូចធំជាច្រើន ដែលយើងឃើញមានអគារខ្លះខ្ពស់ អគារខ្លះទាប អគារខ្លះធំ អគារខ្លះតូចជាដើម។ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺនៅខាងលើអគារនោះគឺមានពពកពណ៌ខ្មៅយ៉ាងធំមួយ អញ្ចឹងពពកពណ៌ខ្មៅ បានន័យថាវាជិតភ្លៀង អញ្ចឹងនៅពេលដែលមេឃអត់ភ្លៀងទេ គឺមានពពកពណ៌ស ដែលនៅពេលដែលមេឃជិតភ្លៀង គឺមានតែងតែមានពពកពណ៌ខ្មៅ ក៏ដូចជាមានខ្យល់ខ្លាំងផងដែរ។ អញ្ចឹងជាទូទៅរដូវវស្សាតែងតែមានពពកខ្មៅ ធំៗ នៅលើអាកាស ឬក៏នៅលើមេឃ ដែលបញ្ជាក់ថាមេឃជិតភ្លៀងហើយ។ អញ្ចឹងនៅក្នុងរូបភាពទីមួយ គឺមានពពកខ្មៅយ៉ាងធំ ដែលគ្របដណ្តប់ទៅលើទីក្រុង។ អញ្ចឹងបានន័យថានៅបន្តិចទៀត គឺនឹងមានភ្លៀងធ្លាក់ជាក់ជាពុំខាន ដោយសារតែមានពពកខ្មៅយ៉ាងធំគ្របដណ្តប់លើទីក្រុង។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា បន្ទាប់ពីមានពពកពណ៌ខ្មៅគ្របនៅលើ ដណ្តប់នៅលើទីក្រុងបានមួយសន្ទុះ យើងឃើញភ្លៀងក៏ចាប់ផ្តើមបង្អុរ អញ្ចឹងមេឃភ្លៀងក៏ចាប់ផ្តើមធ្លាក់ ឬក៏យើងហៅថាមេឃធ្លាក់ភ្លៀង អញ្ចឹងយើងអាចហៅបានពីរ យើងហៅថាមេឃបង្អុរភ្លៀង ឬក៏មេឃធ្លាក់ភ្លៀង។ ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺមេឃ ទឹកភ្លៀងកំពុងតែស្រក់ចេញពីពពក អញ្ចឹងបានន័យថាភ្លៀងស្រក់ចេញពីពពកខ្មៅ ដោយពពកខ្មៅ គឺជាពពកដែលបណ្តុំទៅដោយទឹក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បានន័យថាចំហាយទឹកគឺ[ពូត] ពូនគ្នានៅក្នុងពពកពណ៌ខ្មៅ ហើយនៅពេលដែលពពកពណ៌ខ្មៅនោះផ្ទុំនូវចំហាយទឹកច្រើនពេក អញ្ចឹងទឹកទាំងអស់នោះនឹងធ្ងន់ ហើយធ្លាក់ចុះមកក្រោមដោយយើងហៅថាភ្លៀង។ អញ្ចឹងជាទូទៅនៅពេលដែលយើងឃើញពពកខ្មៅ គឺនឹងមានភ្លៀងធ្លាក់ដូច្នេះយើងអត់ត្រូវរត់លេងនៅខាងក្រៅនោះទេ នៅពេលដែលយើងឃើញពពកខ្មៅគឺយើងត្រូវចូលក្នុងផ្ទះ ហើយសាខោអាវទុកឲ្យអស់ ព្រោះថា ប្រសិនបើមេឃភ្លៀងអាចធ្វើឲ្យយើងសើម ឬក៏អាចធ្វើឲ្យយើងឈឺបាន។ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ២ នេះយើងឃើញពពកខ្មៅកំពុងតែបង្អុរភ្លៀងមកលើទីក្រុង ហើយមានលាយឡំនឹងរន្ទះផងដែរ។ដែលយើងឃើញរន្ទះគឺជា ភ្លើង ភ្លើងដែលបាញ់ចេញពីពពកអញ្ចឹងនៅពេលដែលភ្លើងនោះប៉ះទៅនឹងអ្វីមួយ វាអាចធ្វើឲ្យវត្ថុនោះ ឬក៏អាចធ្វើឲ្យផ្ទះឆេះបាន។ប្រសិនបើរន្ទះបាញ់ចំដើមឈើ គឺអាចធ្វើឲ្យដើមឈើឆេះ ហើយប្រសិនបើរន្ទះបានបាញ់ចំផ្ទះអាចធ្វើឲ្យផ្ទះនោះឆេះ ឬខូចខាត តែប្រសិនបើវាបាញ់ចំមនុស្សវិញវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ដល់ជីវិត ឬក៏វាអាចធ្វើឲ្យយើងស្លាប់បាន។ ដូច្នេះយើងអត់ត្រូវប្រើប្រាស់ទូរទស្សន៍ ឬអត់មើលទូរទស្សន៍ ឬក៏អត់ត្រូវប្រើប្រាស់ទូរស័ព្ទទេនៅពេលមេឃភ្លៀង ព្រោះវាអាចធ្វើឲ្យមានរន្ទះកើតឡើងបាន។អញ្ចឹងប្រសិនបើមានរន្ទះបាញ់ចំមនុស្ស វាអាចធ្វើឲ្យយើងស្លាប់បាន។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ យើងឃើញថាភ្លៀងធ្លាក់ខ្លាំងពេកដោយសារតែភ្លៀងធ្លាក់ខ្លាំង យើងឃើញមានទឹកដក់ជាច្រើននៅតាមផ្លូវហើយយើងឃើញមានមនុស្សម្នាក់កំពុងតែរត់កាត់ភ្លៀង។អញ្ចឹងបានន័យថាគាត់កំពុងតែដើរនៅតាមផ្លូវ បន្ទាប់មកមានភ្លៀងធ្លាក់ដូច្នេះគាត់ត្រូវតែរត់យ៉ាងលឿន ដើម្បីទៅរកកន្លែងជ្រក។ អញ្ចឹងយើងឃើញភ្លៀងបណ្តើរ មនុស្សមានមនុស្សកំពុងតែរត់នៅតាមផ្លូវបណ្តើរ ដើម្បីរត់ទៅរកកន្លែងជ្រកកុំឲ្យសើមភ្លៀង។ដោយសារតែគាត់អត់មានឆត្រ នៅក្នុងរូបភាពនេះ ដោយសារតែគាត់អត់មានឆត្រឬក៏អត់មានអាវភ្លៀងទេ ដូច្នេះគាត់ក៏បានសើមដោយសារទឹកភ្លៀង។ ហើយយើងឃើញនៅតាមផ្លូវនៅលើផ្លូវ គឺមានទឹកដក់ជាច្រើន ព្រោះតែមេឃភ្លៀង អញ្ចឹងវានឹងមានទឹកដក់នៅតាមផ្លូវដែលធ្វើឲ្យយើងពិបាកក្នុងការធ្វើដំណើរ ហើយអាចធ្វើឲ្យយើងវាសើមខោអាវឬក៏ប្រឡាក់ខោអាវបាន នៅពេលដែលយើងជាន់ទឹក ឬក៏ខ្ទាតទឹក ដែលដក់នៅតាមផ្លូវចំយើង។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថាមេឃភ្លៀងធ្វើឲ្យលិចទឹក ជាយ៉ាងជ្រៅ នៅក្នុងទីក្រុង ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺយើងឃើញមានអគារជាច្រើនឬក៏ផ្ទះជាច្រើន ដែលនៅក្នុងរូបភាពនេះ ហើយមានមនុស្សប្រុសស្រីជាច្រើន កំពុងតែដើរនៅក្នុងទឹក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បានន័យថាមានទឹកជំនន់កើតឡើងបន្ទាប់ពីមេឃភ្លៀង។ ដោយយើងឃើញនៅក្បែរផ្ទះនោះ
យើងឃើញមានបុរសម្នាក់ ដែលគាត់ពាក់អាវដៃខ្លី ពណ៌ស ស្លៀកខោពណ៌បៃតង
គាត់កំពុងតែឈរនៅក្នុងទឹក ហើយដៃរបស់គាត់ទាំងពីរ កំពុងតែលើកឡើងលើ ដោយកាន់ឯកសារ
ឬក៏កាន់ថង់អ្វីមួយដើម្បីយកបាំង។ អញ្ចឹងគាត់កាន់លើកឡើងលើ ដើម្បីយកបាំងក្បាលរបស់គាត់
កុំឲ្យមេឃភ្លៀង។ អញ្ចឹងគាត់កាន់ឯកសារ ឬក៏កាន់ក្រដាសអ្វីមួយ
ដើម្បីបាំងមេឃកុំឲ្យភ្លៀងធ្លាក់ទទឹកគាត់ ហើយយើងឃើញនៅក្បែរនោះគឺមាននារីម្នាក់
ដែលគាត់ពាក់អាវដៃវែងពណ៌ទឹកក្រូច ស្លៀកខោពណ៌ស អញ្ចឹងនៅដៃរបស់នារីម្នាក់នោះ
គឺគាត់កំពុងតែកាន់កាបូប ឬក៏[...]កាន់ថង់ចំនួនពីរ អញ្ចឹងគាត់កំពុងតែលើកថង់ ឬក៏កាបូបគាត់ឡើង
គាត់ព្យាយាមលើកឡើងដើម្បីឲ្យផុតពីទឹក
ព្រោះគាត់អត់ចង់ឲ្យកាបូបរបស់គាត់សើមទៅនឹងទឹកនោះទេ ដូច្នេះគាត់លើកឲ្យខ្ពស់
ដើម្បីឲ្យផុតពីទឹកកុំឲ្យសើម ដោយសារតែមេឃភ្លៀង ហើយទីក្រុងគឺត្រូវបានទឹកជំនន់ជន់លិច។
ដែលយើងឃើញរូបភាពនៅកណ្ដាល គឺមានបុរសម្នាក់ទៀតរៀងចំណាស់បន្តិច គាត់ពាក់អាវសដៃខ្លី
ស្លៀកខោពណ៌សជើងខ្លី នៅដៃខាងឆ្វេងរបស់គាត់គឺកំពុងតែកាន់ឆត្រមួយ អញ្ចឹងបុរសម្នាក់នោះ
គាត់កំពុងតែកាន់ឆត្រ គាត់បាំងឆត្រ ដើម្បីកុំឲ្យភ្លៀងសើមគាត់ ឬក៏ដើម្បីកុំឲ្យភ្លៀងទទឹកគាត់
ព្រោះគាត់ខ្លាចឈឺ ប៉ុន្តែគាត់កំពុងតែដើរនៅក្នុងទឹក ដើម្បីទៅរកកន្លែងគោកមួយ
ហើយនៅក្បែរនោះយើងឃើញមាននារីម្នាក់ទៀត ដែលគាត់ស្លៀកសំពត់ពណ៌លឿង ពាក់អាវដៃវែង
ដៃខ្លីពណ៌ស ដោយគាត់កំពុងតែដើរនៅក្នុងទឹក គាត់ដើរលុយទឹកបណ្ដើរ
ដើម្បីទៅដើរទៅរកកន្លែងដែលគោក ដែលអត់មានកន្លែងលិចទឹក។ អញ្ចឹងមេឃភ្លៀង
គឺធ្វើឲ្យមនុស្សពិបាកក្នុងការរស់នៅ បានន័យថាបន្ទាប់ពីមេឃភ្លៀង ធ្វើឲ្យមានទឹកជំនន់ជន់លិច
ដូច្នេះធ្វើឲ្យមនុស្សពិបាកធ្វើដំណើរ និងពិបាករស់នៅជាខ្លាំង។
ដែលជាក់ស្ដែងយើងឃើញនៅក្នុងរូបភាពនេះ គឺម្នាក់ៗគឺកំពុងតែដើរលុយទឹក
ដើម្បីទៅរកកន្លែងគោក ព្រោះនៅក្នុងទឹក គឺពិបាកធ្វើដំណើរ។
ម្យ៉ាងវិញទៀតយើងឃើញសូម្បីតែសត្វឆ្កែ សត្វឆ្កែក៏ពិបាកដែរ យើងឃើញនៅក្នុងរូបភាពនេះ
គឺសត្វឆ្កែកំពុងតែហែលទឹកដើម្បីទៅរកកន្លែងគោក ដោយសារតែទឹកបានលិចខ្លួនវាអស់ហើយ
ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺសត្វឆ្កែនៅសល់តែក្បាលតែប៉ុណ្ណោះ ដែលអណ្ដែតនៅលើទឹក
អញ្ចឹង[គាត់]វាហែលទឹកបណ្ដើរ វាព្យាយាមហែលទឹកដើម្បីឲ្យផុតពីទឹក ដើម្បីទៅរកកន្លែងគោក
ដើម្បីងាយស្រួលក្នុងការរស់នៅ។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ យើងឃើញមានរថយន្តមួយគ្រឿង ឬក៏ឡានមួយគ្រឿង
កំពុងតែបើកបរនៅក្នុងទឹក។ អញ្ចឹងនៅពេលដែលមេឃភ្លៀង យើងឃើញរថយន្តមួយនោះ
គាត់កំពុងតែបើកបរនៅក្នុងទឹកនៅក្រោមមេឃភ្លៀង ដោយយើងឃើញរថយន្តមួយគ្រឿងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺគាត់បើកភ្លើងផងដែរ។ អញ្ចឹងឡាន ឬក៏រថយន្ត គឺមានកង់ចំនួន ៤ ប៉ុន្តែនៅក្នុងរូបភាពនេះ ដោយសារតែយើងមើលពីចំហៀង យើងមើលពីចំហៀង គឺឃើញកង់តែពីរតែប៉ុណ្ណោះ ដោយសារតែវាបាំង។ អញ្ចឹងឡានជាទូទៅ គឺមានទ្វារ និងមានកញ្ចក់ ហើយមានកញ្ចក់សម្រាប់មើលក្រោយផងដែរ ដែលនៅក្នុងរូបភាពនេះ យើងឃើញ យើងឃើញមានកញ្ចក់មើលក្រោយ ហើយឡានកំពុងតែបើកភ្លើង អញ្ចឹងជាទូទៅនៅពេលដែលយើងបើកបរនៅក្នុងមេឃភ្លៀង ឬក៏នៅក្រោមមេឃភ្លៀង ឬក៏នៅក្រោមមេឃងងឹត ឬក៏នៅពេលដែលមានដីហុយ គឺយើងតែងតែបើកភ្លើងជានិច្ច ព្រោះវាអាចធ្វើឲ្យយើងមើលផ្លូវឃើញច្បាស់ ប្រសិនបើយើងអត់បើកភ្លើងទេ គឺយើងអត់អាចមើលផ្លូវឃើញនោះទេ។ ហើយនៅខាងក្រោយ ភ្លើងខាងក្រោយគឺពណ៌ក្រហម អញ្ចឹងភ្លើងខាងក្រោយ គឺអាចធ្វើឲ្យអ្នកដែលនៅខាងក្រោយយើងមើលឃើញយើងបាន ដោយសារតែវាមានពណ៌ក្រហម ដូច្នេះគេអាចមើលមក គេឃើញភ្លើងក្រហម អញ្ចឹងគេដឹងថាមានឡាននៅខាងមុខ។ ហើយនៅពេលដែលយើងបើកឡាននៅក្រោមភ្លៀង គឺតែងតែទឹកសើមកញ្ចក់ អញ្ចឹងយើងពិបាកនៅក្នុងការមើលផ្លូវ អញ្ចឹងយើងត្រូវបើកផ្លិតទឹក ដើម្បីជូតទឹកចេញអំពីកញ្ចក់។ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៥ នេះ យើងឃើញឡាននោះ គឺកំពុងតែបើកផ្លិតទឹក ដើម្បីជូតកញ្ចក់មុខ ដើម្បីឲ្យស្អាត កុំឲ្យមានទឹក ដើម្បីងាយស្រួលក្នុងការមើលផ្លូវ។ ក៏ប៉ុន្តែដោយសារតែឡានបើកនៅក្រោមភ្លៀង ដូច្នេះវាពិបាកក្នុងការបើកបរ ដោយសារតែទឹកលិចផ្លូវ ដូច្នេះឡានអាចបើកទៅយឺតៗតែប៉ុណ្ណោះ ព្រោះពេលខ្លះអាចធ្វើឲ្យផ្លូវរអិល មេឃភ្លៀងអាចធ្វើឲ្យផ្លូវរអិល អញ្ចឹងប្រសិនបើយើងបើកលឿន អាចនឹងមានគ្រោះថ្នាក់បាន។ ដូច្នេះយើងត្រូវតែបើកយឺតៗតែប៉ុណ្ណោះ។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញម៉ូតូកំពុងតែជិះនៅក្នុងទឹកផងដែរ អញ្ចឹងម៉ូតូមួយគ្រឿងកំពុងតែបើកបរ ឬក៏ជិះនៅក្នុងទឹក ដោយយើងឃើញបុរសម្នាក់ គាត់ពាក់អាវពណ៌បៃតងដៃខ្លី ស្លៀកខោជើងវែងពណ៌ស គាត់កំពុងតែជិះម៉ូតូពណ៌សមួយនៅក្រោមភ្លៀង។ ដោយសារតែគាត់អត់បានត្រៀមខ្លួនមុន ដូច្នេះគាត់អត់មានអាវភ្លៀងនោះទេ អញ្ចឹងគាត់អត់មានអាវភ្លៀងនោះទេ គាត់ជិះម៉ូតូ ដែលនៅក្នុងទឹក ដោយជិះកាត់ក្រោមភ្លៀង ដោយយើងឃើញគាត់ពាក់មួកសុវត្ថិភាពពណ៌ទឹកក្រូចផងដែរ។ អញ្ចឹង ម៉ូតូរបស់គាត់ យើងឃើញនៅខាងមុខ នៅជិតដៃចង្កូតគឺមានកញ្ចក់សម្រាប់មើលក្រោយមួយ។ អញ្ចឹងកញ្ចក់សម្រាប់មើលក្រោយ គឺជាកញ្ចក់សម្រាប់ឲ្យយើងអាចដឹងអំពីស្ថានភាពនៅខាងក្រោយម៉ូតូរបស់យើងបាន ដោយយើងអត់ចាំបាច់ងាកខាងក្រោយទេ។ អញ្ចឹងនៅពេលដែលយើងចង់មើលផ្លូវ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏មើលអ្វីដែលនៅខាងក្រោយ យើងគ្រាន់តែក្រឡេកមើលកញ្ចក់ គឺយើងអាចមើលឃើញពុំខាន អញ្ចឹងយើងអត់ចាំបាច់ងាកក្រោយទេ ព្រោះថាប្រសិនបើយើងងាកក្រោយ ពេលខ្លះអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន។ ហើយនៅខាងមុខគឺមានអំពូលភ្លើង ឬក៏ចង្កៀងភ្លើង អញ្ចឹងបុរសម្នាក់នោះគាត់ជិះម៉ូតូកាត់ភ្លៀង ដោយគាត់បើកភ្លើងផងដែរ ព្រោះដើម្បីមើលផ្លូវ ពេលខ្លះគឺពិបាកមើលផ្លូវ ប្រសិនបើយើងអត់បើកភ្លើងនោះទេ ហើយអ្នកដែលនៅខាងមុខ ក៏អត់ដឹងថាយើងកំពុងតែជិះម៉ូតូដែរ អញ្ចឹងគេអត់អាចមើលយើងឃើញ ក៏ប៉ុន្តែប្រសិនបើយើងបើកឃើញ បើយើង បើសិន បើយើងបើកភ្លើង គឺអ្នកនៅខាងមុខគេអាចមើលយើងឃើញផងដែរ ហើយនៅខាងក្រោយគឺយើងឃើញម៉ូតូរបស់គាត់ គឺមានឃ្លុបមួយ អញ្ចឹងឃ្លុបនោះ គឺជាឃ្លុបសម្រាប់ដាក់អីវ៉ាន់ អញ្ចឹងពេលខ្លះគាត់អាចដាក់សៀវភៅ ឬក៏កាតាបរបស់គាត់ ឬក៏អីវ៉ាន់របស់គាត់ផ្សេងៗ ដាក់នៅឃ្លុប នៅក្រោម នៅក្នុងឃ្លុបខាងក្រោយនោះបាន ដោយមិនចាំបាច់ចងខ្សែ ឬក៏មិនចាំបាច់កាន់នោះទេ ដោយឃ្លុបនោះគឺជាប់ទៅនឹងម៉ូតូ ដូច្នេះប្រសិនបើយើងដាក់អីវ៉ាន់ចូលទៅក្នុងឃ្លុប គឺវាអត់ជ្រុះនោះទេ។ អញ្ចឹងម៉ូតូកំពុងតែបើកកាត់ទឹក ហើយម៉ូតូគាត់ត្រូវជិះយឺតៗ ព្រោះថាគាត់អត់អាចមើលផ្លូវឃើញ ដោយសារតែផ្លូវលិចទឹក អញ្ចឹងប្រសិនបើគាត់ជិះលឿន ប្រសិនបើផ្លូវមានក្រឡុក អញ្ចឹងអាចធ្វើឲ្យគាត់ដួលបាន ប្រសិនបើគាត់ជិះធ្លាក់ក្រឡុក អាចធ្វើឲ្យគាត់មានគ្រោះថ្នាក់ ដោយគាត់ដួលម៉ូតូជាដើម អញ្ចឹងគាត់ត្រូវជិះយឺតៗ និងប្រុងប្រយ័ត្នជាទីបំផុត នៅពេលដែលមានមេឃភ្លៀង។

បន្ទាប់មកទៀត រូបភាពទី ៧ រូបភាពទី ៧ យើងឃើញមានមនុស្សចំនួនពីរនាក់ មនុស្សប្រុសម្នាក់ និងមនុស្សស្រីម្នាក់ ដោយមនុស្សស្រីនោះគឺគាត់មានវ័យរៀងចំណាស់បន្តិច គាត់កំពុងតែដើរកាត់ទឹក បានន័យថាទឹកជំនន់នៅក្នុងទីក្រុងនៅពេលដែលមេឃភ្លៀង អញ្ចឹងគាត់ដើរបណ្តើរ គាត់កាន់ឆត្របណ្តើរដើម្បីបាំង។ អញ្ចឹងស្ត្រីចំណាស់ម្នាក់ អាយុគាត់ប្រហែលជា ៥០ ឆ្នាំ ដោយគាត់ពាក់អាវស ដៃវែង ហើយស្លៀកសំពត់ពណ៌សផងដែរ គាត់កំពុងតែដើរកាត់ទឹក ដោយកាន់ឆត្រពណ៌លឿង អញ្ចឹងដោយសារតែគាត់ត្រូវធ្វើដំណើរនៅពេលមេឃភ្លៀង ដូច្នេះដើម្បីការពារកុំឲ្យសើមអាវ ឬក៏សើមខ្លួនរបស់គាត់ គាត់ត្រូវបាំងឆត្រ គាត់យកឆត្រមកបាំងដើម្បីកុំឲ្យសើមខ្លួន ក៏ប៉ុន្តែជើងរបស់គាត់នៅតែសើម ដោយសារតែមេឃភ្លៀង ធ្វើឲ្យទឹកលិចផ្លូវ ឬក៏មានទឹកជំនន់ ដូច្នេះគាត់ត្រូវដើរកាត់ទឹក អញ្ចឹងហើយធ្វើឲ្យគាត់សើមខាងជើង សើមជើងរបស់គាត់ ចំណែកឯនៅក្បែរគាត់គឺមានក្មេងប្រុសម្នាក់ ដែលគាត់មើលទៅអាយុប្រហែលជាម្ភៃឆ្នាំ អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់ពាក់អាវសដៃខ្លី ស្លៀកខោពណ៌ខ្មៅជើងវែង គាត់កាន់ឆត្រមួយដែរ កំពុងតែដើរនៅក្នុងទឹក ដោយសារតែមេឃភ្លៀង ដូច្នេះហើយគាត់ត្រូវតែកាន់ឆត្រ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីកុំឲ្យសើមខ្លួន ឬក៏កុំឲ្យទទឹកសម្លៀកបំពាក់របស់គាត់ ដោយគាត់ដើរបណ្ដើរ
គាត់បាំងឆត្របណ្ដើរ ហើយគាត់ងើយមើលខាងលើ អញ្ចឹងគាត់ងើយមើលខាងលើ
គាត់ចង់ដឹងថាតើមេឃរាំងហើយឬនៅ។

បន្ទាប់មកទៀតរូបភាពទី ៨ នៅរូបភាពទី ៨ យើងឃើញមានជើងមួយ យើងឃើញជើងមួយនោះ
គាត់កំពុងតែដើរជាន់ទឹកដែលដក់ អញ្ចឹងបានន័យថា នៅពេលដែលមេឃភ្លៀង
គឺមានទឹកដក់គ្រប់ទីកន្លែង ដូច្នេះនៅពេលដែលយើងដើរ យើងត្រូវតែប្រុងប្រយ័ត្ន
ព្រោះពេលខ្លះទឹកដក់នៅលើផ្លូវវាអាចធ្វើឲ្យមានភក់ ឬក៏មានល្បាប់។
អញ្ចឹងនៅពេលដែលយើងជាន់លើល្បាប់ ឬក៏ជាន់លើភក់
វាអាចធ្វើឲ្យភក់នោះខ្ទាតចេញមកប្រឡាក់ខោអាវរបស់យើងបាន។ ភក់ឬល្បាប់ វាកើតចេញពីដី
ដែលនៅលើថ្នល់ ដែលដីនោះគឺវាត្រូវទឹក វាអាចធ្វើឲ្យមានសភាពខាប់ ឬក៏អន្ទិលៗ
បែកអេក[បែក...]។ អញ្ចឹងវាខ្ទាតនៅពេលដែលយើងជាន់ខ្លាំង វាអាចនឹងខ្ទាត ធ្វើឲ្យវាប្រឡាក់អាវ។
ដែលជាក់ស្ដែងនៅក្នុងរូបភាពនេះ គឺមានជើងកំពុងតែជាន់ភក់ ឬក៏ជាន់ទឹកដក់ដែលនៅតាមផ្លូវ
អញ្ចឹងទឹកនោះនឹងខ្ទាត នឹងខ្ទាតមកប្រឡាក់ខោរបស់យើង ឬក៏ខ្ទាតប្រឡាក់ទៅសម្លៀកបំពាក់
ដែលនៅ អ្នកដែលនៅជិតយើងផងដែរ ដូច្នេះបន្ទាប់ពីមេឃភ្លៀង យើងត្រូវតែប្រុងប្រយ័ត្ន
ដើរមើលខាងក្រោម ឬក៏ដើរមើលផ្លូវ ហើយមិនត្រូវជាន់ភក់ ឬក៏ជាន់ទឹកដក់នៅតាមផ្លូវនោះទេ
ព្រោះវាអាចធ្វើឲ្យយើងប្រឡាក់ខោអាវបាន។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថាមេឃភ្លៀង
យើងឃើញមានក្មេងប្រុសចំនួនពីរនាក់ កំពុងតែរត់លេងកាត់ភ្លៀង។ អញ្ចឹងជាទូទៅ
ក្មេងៗគឺគាត់ចូលចិត្តលេងទឹកភ្លៀង។ គាត់រត់ ចូលចិត្តលេងងូតទឹកភ្លៀង
ដោយគាត់ប្រលែងគ្នានៅក្រោមទឹកភ្លៀង។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ
ជាក់ស្ដែងនៅក្នុងរូបភាពនេះ គឺមានក្មេងប្រុសពីរនាក់ កំពុងតែដេញចាប់គ្នានៅក្រោមទឹកភ្លៀង
ដោយពួកគេទាំងពីរអ្នកគឺប្រលែងគ្នាលេង បានន័យថារត់ប្រលែងគ្នានៅក្រោមទឹកភ្លៀង
ដោយពួកគេអត់មានពាក់អាវនោះទេ។ អញ្ចឹងក្មេងប្រុសដែលនៅខាងមុខ
គឺគាត់ស្លៀកខោជើងខ្លីពណ៌ស អត់មានពាក់អាវនោះទេ ហើយគាត់រត់បណ្ដើរ
គាត់ងាកក្រោយបណ្ដើរ ដោយយើងឃើញគាត់កំពុងតែរត់ ហើយដៃទាំងពីររបស់គាត់គឺបោះទៅមុខ
ប៉ុន្តែមុខរបស់គាត់គឺងាកមកក្រោយ ដោយសម្លឹងមើលក្មេងប្រុសម្នាក់ទៀត
ដែលស្លៀកខោជើងខ្លីពណ៌ទឹកក្រូច ក៏ប៉ុន្តែគាត់ក៏អត់មានពាក់អាវដែរ។
អញ្ចឹងក្មេងប្រុសដែលស្លៀកខោជើងខ្លីពណ៌ទឹកក្រូច
កំពុងតែរត់ដេញចាប់ក្មេងប្រុសដែលស្លៀកខោពណ៌ស គឺពួកគេកំពុងតែរត់ប្រលែងគ្នាលេងនៅតាម

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្រោមទឹកភ្លៀង។ អញ្ចឹងជាទូទៅក្មេងៗគឺគាត់ ឲ្យតែមានមេឃភ្លៀង
អញ្ចឹងពួកគាត់ឲ្យតែមានមេឃភ្លៀង គឺពួកគាត់ចូលចិត្តងូតទឹកភ្លៀងខ្លាំងណាស់
ដោយសារតែវាសប្បាយ គាត់គិតថាសប្បាយ អញ្ចឹងគាត់តែងតែរត់លេងនៅក្រោមទឹកភ្លៀង
រត់ប្រលែងគ្នា ក៏ប៉ុន្តែមេឃភ្លៀង គឺអត់សូវល្អនោះទេ ប្រសិនបើយើងត្រូវទឹកភ្លៀងយូរ
វាអាចធ្វើឲ្យយើងឈឺបាន អញ្ចឹងវាអាចធ្វើឲ្យយើងផ្ដាសាយ វាអាចធ្វើឲ្យយើងក្ដៅខ្លួន
ឬក៏អាចធ្វើឲ្យយើងហៀរសំបោរបាន ប្រសិនបើយើងត្រូវទឹកភ្លៀងយូរ។
ដូច្នេះយើងអត់ត្រូវងូតទឹកភ្លៀងនោះទេ នៅពេលដែលមានមេឃភ្លៀង។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ គឺជារូបភាពដែលទឹកជំនន់កើនឡើង
អញ្ចឹងបានន័យថានៅពេលដែលមានមេឃភ្លៀងខ្លាំង គឺទឹកនឹងឡើងខ្ពស់ ដែលរូបភាពទី ១០ នេះ
យើងឃើញជាទំនប់ទឹក បានន័យថាជាអាងទប់ទឹកមួយ កុំឲ្យទឹកហូរចូលទីក្រុង។
អញ្ចឹងប្រសិនបើមានភ្លៀងខ្លាំង នោះកម្ពស់ទឹកនឹងកើនឡើង។
ដែលជាក់ស្ដែងយើងឃើញនៅក្នុងរូបភាពនេះ គឺទំនប់ទឹកម្ខាងគឺមានទឹកកំពុងតែឡើងខ្ពស់
ដោយសារតែមានមេឃភ្លៀងហូរចូលខ្លាំង ចំណែកឯម្ខាងទៀតគឺអត់សូវមានទឹកនោះទេ
អញ្ចឹងទំនប់ទឹក គឺគេទប់កុំឲ្យទឹកហូរពីខាងក្រៅចូលទៅក្នុងទីក្រុងបាន
ក៏ប៉ុន្តែប្រសិនបើមានភ្លៀងខ្លាំងពេក អញ្ចឹងប្រសិនបើមានភ្លៀងខ្លាំងពេក គឺកន្លែងទប់ទឹកនោះ
គឺទប់អត់ជាប់នោះទេ ដោយសារតែទឹកឡើងខ្ពស់ខ្លាំង ដូច្នេះវាអាចនឹងហៀរចូលទីក្រុង។
អញ្ចឹងប្រសិនបើទឹកឡើងខ្ពស់ខ្លាំង វានឹងហៀរចូលទីក្រុង ធ្វើឲ្យទីក្រុងនឹងលិចទឹកជាក់ជាមិនខាន។
ដែលជាក់ស្ដែងនៅក្នុងរូបភាពនេះ គឺទឹក កម្ពស់ទឹកកំពុងតែឡើងខ្ពស់
បានន័យថាទឹកកំពុងតែឡើងខ្ពស់ខ្លាំង ដោយសារតែមានភ្លៀងខ្លាំងនៅក្នុងថ្ងៃនេះ។
អញ្ចឹងទឹកអាចនឹងហៀរចូលទីក្រុង និងធ្វើឲ្យមានទឹកជំនន់នៅក្នុងទីក្រុងទៀតផង
ព្រោះថាប្រសិនបើទឹកឡើងខ្លាំងពេកនោះ ទំនប់ទឹកមិនអាចទប់ទឹកជាប់នោះទេ
អញ្ចឹងប្រសិនបើទំនប់ទឹកអត់អាចទប់ទឹកជាប់ ទឹកនឹងហៀរចូលទៅពន្លិចទីក្រុង
ដែលធ្វើឲ្យទីក្រុងមានទឹកលិច។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ គឺយើងឃើញមានក្មេងប្រុសម្នាក់ គាត់កំពុងតែឈរនៅ
តាមបង្អួច អញ្ចឹងប្រហែលជា នេះគឺជារូបភាពដែលនៅជនបទ ឬក៏នៅស្រុកស្រែចំការ
អញ្ចឹងយើងឃើញមានក្មេងប្រុសម្នាក់ គាត់កំពុងតែឈរនៅក្បែរបង្អួច
គាត់កំពុងតែឈរមើលទៅមកក្រៅ មកមើលភ្លៀងធ្លាក់។ អញ្ចឹងគាត់ឈរនៅក្នុងផ្ទះរបស់គាត់
ដោយគាត់ឈរសម្លឹងមកក្រៅតាមបង្អួចមើលភ្លៀងធ្លាក់ ដោយយើងឃើញនៅខាងក្រៅផ្ទះរបស់គាត់
គឺយើងឃើញមានពាងធំមួយ យើងហៅថាពាង។ អញ្ចឹងពាងធំនោះ គាត់កំពុងតែត្រង ត្រងទឹក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីឲ្យមានទឹកចូលទៅក្នុងពាង។ ដោយជាទូទៅនៅតាមទីជនបទ គឺយើងប្រើប្រាស់ទឹកភ្លៀង និយមប្រើប្រាស់ទឹកភ្លៀង។ អញ្ចឹងនៅពេលដែលយើងធ្វើផ្ទះ គឺដំបូលផ្ទះ គឺយើងតែងតែមានដាក់ទមួយ ដើម្បីបង្ហូរទឹកចូលទៅក្នុងពាង។ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១១ នេះ យើងឃើញទឹកភ្លៀងកំពុងតែស្រក់នៅលើដំបូល ហើយទឹកដែលស្រក់នៅលើដំបូល បានហូរតាមទចូលទៅក្នុងពាង ដោយយើងឃើញទឹកកំពុងតែហូរចូលទៅក្នុងពាង ដោយហូរតាមទចូលទៅក្នុងពាង ដោយពេលនោះគឺជាមេឃភ្លៀង ដែលយើងឃើញនៅក្បែរពាងនោះ គឺយើងឃើញមានទឹកដក់ជាច្រើននៅលើដី អញ្ចឹងទឹកដក់នៅលើដីវានឹងបង្កទៅជាល្បាប់ ឬក៏ទៅជាភក់ ដែលធ្វើឲ្យយើងប្រឡាក់ នៅពេលដែលយើងជាន់ចំវា។ ដូច្នេះមេឃភ្លៀងគឺធ្វើឲ្យដីទៅជាល្បាប់ ឬក៏ទៅជាភក់ អញ្ចឹងវាពិបាកនៅក្នុងការធ្វើដំណើរ និងនៅក្នុងការរស់នៅ ក៏ប៉ុន្តែដើមឈើនៅជិតនោះ គឺមានសភាពស្រស់បំព្រង ពណ៌បៃតង ដោយសារតែមេឃភ្លៀង គឺធ្វើឲ្យដើមឈើគឺមានពណ៌បៃតង។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺប្រហែលជានៅជនបទ ព្រោះយើងឃើញមានពាងធំមួយសម្រាប់ដាក់ទឹក ដែលជាទូទៅ គឺនៅជនបទគឺសម្បូរពាងសម្រាប់ដាក់ទឹក ដោយសារតែគាត់អត់មានម៉ាស៊ីនទឹក ម៉ាស៊ីនប្រើប្រាស់។ អញ្ចឹងដើម្បី វិធីដើម្បីយកទឹកភ្លៀង គឺយើងត្រូវប្រើទ ដាក់នៅក្រោមដំបូល ដើម្បីឲ្យទឹកហូរចូល ពីលើដំបូលចូលមកក្នុងទ ហើយបង្ហូរចូលទៅក្នុងពាង។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញមានកសិករ គាត់កំពុងតែស្ទូងស្រូវ។ អញ្ចឹងរដូវវស្សា ឬក៏រដូវភ្លៀង គឺជារដូវដែលកសិករចាប់ផ្តើមធ្វើស្រែ ដោយសារតែមានភ្លៀងធ្លាក់។ អញ្ចឹងនៅក្នុងប្រទេសកម្ពុជា គឺជាប្រទេសដែលប្រកបរបរកសិកម្ម ដោយយើងឃើញប្រជាជនប្រមាណជា ៩០ ភាគរយ គឺសុទ្ធតែជាប្រកបរបរធ្វើស្រែ ឬក៏ប្រកបរបរកសិកម្ម ដែលដាំដំណាំផ្សេងៗ ដូចជាដាំស្រូវ ដាំពោត ដាំសណ្តែកជាដើម។ អញ្ចឹងដរាបណាមេឃអត់ទាន់ភ្លៀង ពួកគាត់អត់អាចធ្វើស្រែបាននោះទេ អញ្ចឹងខែប្រាំង គឺពួកគាត់អត់អាចធ្វើស្រែបាននោះទេ ក៏ប៉ុន្តែខែវស្សា ដែលជាខែភ្លៀង គឺពួកគាត់អាចធ្វើស្រែបាន ដូច្នេះ នៅពេលដែលមានភ្លៀង គឺយើង ពួកកសិករគឺសប្បាយចិត្ត ហើយចាប់ផ្តើមការងារស្រែចំការរបស់ពួកគាត់។ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១២ គឺយើងឃើញមានបុរសម្នាក់ ដែលជាកសិករ គាត់កំពុងតែឱនស្ទូងស្រូវ។ អញ្ចឹងការស្ទូងស្រូវ គឺជាការយកដើមស្រូវដោតចូលទៅក្នុងស្រែ ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺដៃទាំងពីររបស់កសិករនោះ គឺគាត់កំពុងតែកាន់សំណាប ដើមសំណាប ឬក៏កូនស្រូវ។ អញ្ចឹងស្រូវ នៅពេលដែលវាដុះតូចបន្តិច យើងហៅថាសំណាប អញ្ចឹងយើងត្រូវដកសំណាបនោះយកមកស្ទូង ដោយយើងដកសំណាបមកហើយ យើងយកមកដោតចូលនៅក្នុងស្រែ ដែលមានដីភក់ៗ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏មានទឹកបន្តិចបន្តួច អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពនេះ គឺកសិករនោះ
គឺគាត់ពាក់អាវពណ៌ទឹកក្រូច ដៃវែង ខោជើងវែងពណ៌ស
ហើយគាត់មានពាក់មួកធំមួយនៅលើក្បាលផងដែរ។ ដោយសារតែនៅវាលស្រែ ពេលខ្លះគឺក្តៅ
ទោះបីជាមានភ្លៀងក៏ដោយ នៅពេលដែលរាំងភ្លៀងគឺវាក្តៅ ដូច្នេះគាត់ត្រូវតែពាក់អាវដៃវែង
ខោជើងវែង និងពាក់មួកដើម្បីការពារកម្តៅ ព្រោះប្រសិនបើគាត់អត់ការពារកម្តៅទេ កម្តៅថ្ងៃ
អាចធ្វើឲ្យគាត់រលាក ឬក៏អាចធ្វើឲ្យគាត់ខ្មៅបាន។ ដូច្នេះគាត់ត្រូវតែការពារកម្តៅនៅ[គាត់]
នៅពេលដែលគាត់ធ្វើស្រែ។ ដោយយើងឃើញកសិករនោះ គាត់កំពុងតែឱន ដោយឱនស្ទូងស្រូវ
ដោយដៃរបស់គាត់ គឺកាន់ដើមស្រូវ ដើម្បីដោតចូលទៅក្នុងស្រែ អញ្ចឹងការដោតដើមស្រូវ
ឬក៏ដោតសំណាបចូលទៅក្នុងស្រែ យើងហៅថាស្ទូង។ ដោយយើងឃើញនៅក្បែរគាត់
គឺមានស្រែជាច្រើនទៀតរបស់កសិករផ្សេង ដែលគេស្ទូងស្រូវរួចហើយ។
អញ្ចឹងយើងឃើញដើមស្រូវគឺមានពណ៌បៃតង។ អញ្ចឹងរដូវវស្សា
គឺជារដូវដែលកសិករប្រកបរបរកសិកម្ម គឺគាត់ចាប់ផ្តើមការងារស្រែចំការរបស់គាត់
ដោយអ្នកស្រែគាត់ដាំស្រូវ រីឯអ្នកចំការ គាត់ដាំដំណាំផ្សេងៗ ដូចជាស្វាយ ដូចជាល្ហុង ដូចជាពោត
សណ្តែកជាដើម។ អញ្ចឹងរាល់ដំណាំកសិកម្មទាំងអស់ គឺកសិករតែងតែដាំនៅក្នុងរដូវវស្សា។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញមានមូសមួយ
អញ្ចឹងសត្វមូសគឺជាសត្វមួយ ដែលជាសត្វល្អិតមួយ ដែលមានគ្រោះថ្នាក់
ដោយវាអាចចម្លងជំងឺផ្សេងៗមកដល់មនុស្សបាន ដូចជាមូសយើងឃើញមានពីរប្រភេទ គឺជាមូសខ្លា
និងមូសដែកគោល។ អញ្ចឹងមូស ភាគច្រើនដែលមកខាំមនុស្ស គឺជាមូសញី។ អញ្ចឹងមូសខ្លាញី
ឬក៏មូសដែកគោលញី ដោយមូសឈ្មោលគឺវាអត់ខាំមនុស្សទេ មូសឈ្មោលគឺវាបឺតលំអងផ្កា
ក៏ប៉ុន្តែមូសញី គឺវាខាំមនុស្សបឺតយកឈាម។ អញ្ចឹងជាទូទៅមូសគឺតែងតែបង្កឲ្យមានជំងឺផ្សេងៗ
ដូចជាជំងឺគ្រុនឈាម និងជំងឺគ្រុនចាញ់ជាដើម ដោយមូសខ្លា គឺបង្កឲ្យមានជំងឺគ្រុនឈាម
ដែលមូសដែកគោល គឺមាន បង្កឲ្យមានជំងឺគ្រុនចាញ់។ អញ្ចឹងនៅក្នុងរូបភាពទី ១៣
យើងឃើញមានមូសមួយ ដែលមូសនោះគឺយើងឃើញមានជើងវាវែងៗ ជើងវែងៗចំនួនបួន
ចំនួនប្រាំបី អញ្ចឹងជើងមូសគឺមានចំនួនប្រាំបី ហើយវែងៗ ហើយនៅលើខ្នងរបស់វាគឺមានស្លាបពីរ
អញ្ចឹងវាមានស្លាបចំនួនពីរនៅលើខ្នងសម្រាប់ហោះហើរ ហើយមាត់របស់វាគឺមានចំពុះមួយ ចំពុះ
ឬក៏ម្ជុលមួយសម្រាប់បឺតឈាមមនុស្ស នៅពេលដែលវាខាំ។ អញ្ចឹងមូសគឺមានខ្លួនបង្កង់ៗ
ហើយមូសខ្លា គឺវាតែងតែខាំមនុស្សនៅពេលថ្ងៃ។ អញ្ចឹងពេលថ្ងៃ ប្រសិនបើយើងគេង
នៅកន្លែងណាដែលអត់មានពន្លឺចេញចូលគ្រប់គ្រាន់ នោះមូសនឹងខាំយើងបាន
ដោយនៅពេលដែលយើងគេងនៅកន្លែងអត់មានពន្លឺ ហើយយើងអត់បានពាក់អាវដៃវែង
ខោជើងវែងនោះទេ អញ្ចឹងមូសខ្លាអាចខាំយើង ហើយអាចចម្លងជំងឺគ្រុនឈាមបាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងជំងឺគ្រុនឈាម នៅពេលដែលយើងព្យាបាលអត់ទាន់ វាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ដល់ជីវិត ដែលយើងអាចស្លាប់បាន ដោយសារតែយើងអត់បានព្យាបាលអត់ទាន់ពេលវេលា។ អញ្ចឹងនៅពេលថ្ងៃយើងត្រូវពាក់អាវដៃវែង ខោជើងវែង ហើយត្រូវនៅកន្លែងដែលមានបន្លឺចេញចូលគ្រប់គ្រាន់ ព្រោះប្រសិនបើអត់មានពន្លឺទេ មូសខ្លាអាចខាំយើងបាន។ ហើយមូសខ្លា គឺភាគច្រើនគឺខាំតែពេលថ្ងៃតែប៉ុណ្ណោះ ចំណែកឯពេលយប់ គឺមានមូសដែកគោល អញ្ចឹងមូសដែកគោលចូលចិត្តខាំមនុស្សនៅពេលយប់។ ហើយនៅពេលដែលមូសដែកគោលខាំ គឺយើងអាចឆ្លងជំងឺគ្រុនចាញ់បាន។ អញ្ចឹងគ្រុនចាញ់វាអាចធ្វើឲ្យយើងរងា និងក្ដៅខ្លួន ហើយអាចធ្វើឲ្យយើងស្លាប់បាន ប្រសិនបើយើងព្យាបាលអត់ទាន់ពេលវេលានោះទេ។ អញ្ចឹងជាទូទៅ ទាំងពេលថ្ងៃនិងពេលយប់ យើងត្រូវប្រុងប្រយ័ត្ននៅក្នុងខែវស្សា ព្រោះខែវស្សា គឺជាខែដែលមានទឹកដក់ច្រើន អញ្ចឹងនៅពេលដែលមានទឹកដក់ មូសអាចពងនៅក្នុងទឹកដក់នោះ ដែលទៅជាដង្កូវទឹក អញ្ចឹងនៅពេលដែលដង្កូវទឹកនៅក្នុងទឹកបានមួយសប្ដាហ៍ ឬក៏រយៈពេល ៧ ថ្ងៃ នោះដង្កូវទឹកនឹងញាស់ទៅជាមូស ដូច្នេះមូសអាចនឹងខាំយើងបានគ្រប់ពេល។ ដូច្នេះនៅក្នុងរដូវវស្សា យើងត្រូវតែប្រុងប្រយ័ត្ន យើងត្រូវពាក់អាវវែង អាវដៃវែង ខោជើងវែង ហើយនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់ ដើម្បីចៀសវាងកុំឲ្យមូសខាំ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ យើងឃើញថា បន្ទាប់ពីមេឃភ្លៀងរួចហើយ បន្ទាប់ពីមេឃភ្លៀង មេឃក៏ចាប់ផ្ដើមស្រឡះ។ អញ្ចឹងយើងឃើញពពកខ្មៅទាំងអស់ កំពុងតែរសាត់ចេញពីព្រះអាទិត្យ។ អញ្ចឹងយើងឃើញព្រះអាទិត្យកំពុងតែបញ្ចេញពន្លឺ ឬក៏បញ្ចេញរស្មីមកវិញ ដូច្នេះបានន័យថាមេឃភ្លៀង លែង មេឃលែងភ្លៀងហើយ អញ្ចឹងយើងឃើញមេឃចាប់ផ្ដើមស្រឡះបន្តិចម្ដងៗ ហើយពពកខ្មៅក៏ចាប់ផ្ដើមរសាត់ចេញ ពពកសក៏ចាប់ផ្ដើមរសាត់ចូលមកវិញ។ អញ្ចឹងបន្ទាប់ពីភ្លៀង មេឃស្រឡះ ដែលយើងឃើញនៅក្នុងសុភាសិតខ្មែរក៏បាននិយាយថា ក្រោយភ្លៀង មេឃស្រឡះ។ អញ្ចឹងអត់មានពពកខ្មៅទៀតទេ នៅពេលដែលអត់មានពពកខ្មៅ គឺយើងបានន័យថា មេឃក៏លែងភ្លៀងដែរ។ ដូច្នេះព្រះអាទិត្យក៏ចាប់ផ្ដើមបញ្ចេញពន្លឺមកលើផែនដីម្ដងទៀត ដោយពុំមានមេឃភ្លៀងនោះទេ ដោយបានន័យថាភ្លៀងរាំងហើយ។

ចំណែកឯបន្ទាប់មកទៀត គឺរូបភាពចុងក្រោយ គឺរូបភាពទី ១៥ អញ្ចឹងរូបភាពទី ១៥ យើងឃើញថាបន្ទាប់ពីមេឃភ្លៀងរាំងហើយ យើងឃើញធម្មជាតិទាំងអស់គឺមានពណ៌បៃតង ដោយយើងឃើញព្រះអាទិត្យកំពុងតែបញ្ចេញពន្លឺ ឬក៏បញ្ចេញរស្មីមកលើធម្មជាតិពណ៌បៃតង ដែលយើងឃើញនៅខាងក្រោម គឺមានភ្នំ និងមានដើមឈើជាច្រើនពណ៌បៃតង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងមេឃភ្លៀងធ្វើឲ្យរុក្ខជាតិទាំងអស់គឺមានពណ៌បៃតង បានន័យថារុក្ខជាតិគឺត្រូវការទឹកដើម្បីរស់
គឺទឹកនិងពន្លឺព្រះអាទិត្យ គឺជាចំណីរបស់រុក្ខជាតិ។ អញ្ចឹងនៅពេលដែលមានភ្លៀង
គឺបានន័យថាចំណីរបស់រុក្ខជាតិ រុក្ខជាតិបានទទួលចំណី
អញ្ចឹងវាអាចធ្វើឲ្យរុក្ខជាតិទាំងអស់គឺរស់បានល្អ។ អញ្ចឹងវាបានធ្វើឲ្យរុក្ខជាតិរស់បានល្អ ដូច្នេះ
ដូច្នេះនៅក្នុងខែវស្សា គឺរុក្ខជាតិទាំងអស់គឺស្រស់បំព្រង គឺមានពណ៌បៃតង
ហើយដើមឈើទាំងអស់គឺចាប់ផ្ដើមលាស់ឡើងវិញ បានន័យថាវាលាស់ខ្ចីឡើងវិញ។
អញ្ចឹងជាទូទៅខែវស្សា គឺជាខែដែលមានធម្មជាតិស្រស់ស្អាត ដោយសារតែវាមេឃភ្លៀង
អញ្ចឹងធម្មជាតិក៏ចាប់ផ្ដើមលាស់ពណ៌បៃតងខ្ចី ហើយកសិករក៏ចាប់ផ្ដើមធ្វើស្រែចំការផងដែរ
ក៏ប៉ុន្តែសម្រាប់ដែលអ្នករស់នៅទីក្រុង គឺគាត់ពិបាកនៅក្នុងការរស់នៅ ដោយសារតែមេឃភ្លៀង
គឺធ្វើឲ្យគាត់ពិបាកក្នុងការធ្វើដំណើរ ក៏ដូចជាទៅណាមកណា គឺមានការពិបាក
ក៏ប៉ុន្តែអ្នកដែលនៅតាមជនបទ គឺគាត់ចូលចិត្តរស់នៅនៅពេលដែលមេឃភ្លៀង
ដោយសារតែគាត់អាចចាប់ផ្ដើមមុខរបរកសិកម្មរបស់គាត់បាន។ អញ្ចឹងមេឃភ្លៀង
គឺផ្ដល់អត្ថប្រយោជន៍ដល់អ្នកនៅស្រែចំការ ក៏ប៉ុន្តែអ្នកនៅទីក្រុងអត់សូវចូលចិត្តមេឃភ្លៀងនោះទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.